ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកគងពិសី នៃខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកគងពិសី នៃខេត្តកំពង់ស្ពឺ ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោម:

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **ម៉ែន ឡើន** | ២៥-០២-១៩៨៩ | ជាប្រធានក្រុមប្រឹក្សាស្រុក |
| ២- | លោក **ម៉ែន ពុំ** | ១២-១០-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៣- | លោក **ចាប ឡើន** | ១៥-០៣-១៩៤៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |

| | | | |
|---|---|---|---|
| ៤- | លោក **សាត់ ស៊ីម** | ១៨-១០-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៥- | លោក **អែវ ប្រាក់** | ០៣-០៤-១៩៤៨ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៦- | លោកស្រី **នៅ ខេន** | ០៥-០៣-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៧- | លោក **អ៊ិន ចំណាប់** | ០៥-០៧-១៩៦៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៨- | លោក **ពេជ្រ ណុន** | ០៦-០១-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៩- | លោកស្រី **យ៉ន ឈឹម** | ១២-០៩-១៩៧០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១០- | លោក **ស្វាយ ឌី** | ០៥-០១-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១១- | លោក **ឃិន សារឿន** | ១៥-១១-១៩៦០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១២- | លោក **ឡេង យុទ្ធ** | ១៦-០៩-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៣- | លោក **ទិត ណី** | ១៥-០១-១៩៤៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៤- | លោក **ស សំឡុត** | ០១-០១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៥- | លោក **ឆ្វ ម៉ុនធឿន** | ០៥-០៦-១៩៦៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៦- | លោក **ជា ចាន់ថុន** | ០១-០១-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៧- | លោក **លុយ អ៊ីម** | ០១-០១-១៩៧១ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៨- | លោក **អាត់ ចន** | ១៤-១០-១៩៤៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៩- | លោក **ប្រាក់ ម៉ុនថៃ** | ១០-០៣-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក។ |

**មាត្រា ២.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកគងពិសី នៃខេត្តកំពង់ស្ពឺ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ